●●● ក្នុងនាមជាសមាជិកនៃគណកម្មាការចម្រុះ និងក្នុងនាមជាអ្នកយកព័ត៌មានផងនោះ នៅព្រឹកថ្ងៃអាទិត្យទី១ ខែមិថុនា កន្លងមកនេះ យើង (អ៊ឹម លឿម) បានបំពេញនូវកាតព្វកិច្ចដ៏ចម្បងមួយក្នុងការធ្វើដំណើរលើកំណាត់ផ្លូវដ៏វែងអន្លាយចេញពីខេត្តកំពង់ស្ពឺ ដែលជាខេត្តមួយពោរពេញទៅដោយដើមត្នោតដ៏ច្រើនជាងគេឆ្ពោះទៅកាន់ខេត្តឧត្តរមានជ័យដែលនៅទាំងនោះឆ្ពោះទៅកាន់ប្រទេសកម្ពុជា ដើម្បីធ្វើសកម្មភាពមនុស្សធម៌ដល់បងប្អូនជនភៀសសឹកខ្មែរយើងនៅឯខេត្តឧត្តរមានជ័យ ។ ថ្ងៃបុណ្យចូលឆ្នាំដំបូង (១៣ ខែ មេសា) ជាថ្ងៃដែលយើងបានឈានជើងជាន់លើមាតុភូមិកំណើតលើកទី៤ក្នុងអំឡុងពេល៩ឆ្នាំ ដែលបានមករស់នៅឯសហរដ្ឋអាមេរិក ។ ហើយនៅថ្ងៃដំបូងនោះបន្ទាប់ពីបានងូតទឹកជម្រះកាយរួចរាល់ហើយ យើងក៏បានទីនោះ ត្រូវបានគេដឹងថា មានជនភៀសសឹករាប់ពាន់គ្រួសារ ដែលពួកគាត់បានចាក់ចេញពីផ្ទះសម្បែងទៅកាន់ទីដ្ឋានដែលពួកគាត់យល់ថា ជាកន្លែងមានសុវត្ថិភាព។





គោលបំណងរបស់យើង គឺគ្មានអ្វីក្រៅពីកិច្ចការមនុស្សធម៌ឡើយព្រោះយើងជាខ្មែរមានបេះដូងជាខ្មែរ មានឈាមជ័រជាខ្មែរ មានសន្ដានជាខ្មែរមានសារតាជាខ្មែរ... ហេតុនេះ គឺចាំបាច់យើងត្រូវចេះជួយធុរៈគ្នាក្នុងខណៈដែលមនុស្សខ្មែរ ដូចគ្នាកំពុងមានទុក្ខអាសន្នអន់ក្រ...។ ក៏ប៉ុន្តែមុននឹងបន្តសាច់រឿងតទៅមុខទៀត នោះក្នុងនាមជាតំណាងពលរដ្ឋខ្មែរក្នុងសហគមន៍ហ្វីឡាដែលហ្វៀដែលបានចូលរួមធ្វើកិច្ចការមនុស្សធម៌នេះសូមឆ្លៀតឱកាសសំដែងនូវអំណរគុណដ៏អនេកប្បការចំពោះសប្បុរសជនក្នុងសហគមន៍ដ៏តូចចង្អៀតមួយនេះ ដែលបានចូលរួមជួយរំលែកធ្វើវិភាគទានសប្បុរសធម៌ដល់ជនភៀសសឹកខ្មែរយើងនៅឯ-ខេត្តឧត្តរមានជ័យ តាមរយៈការធ្វើបុណ្យទក្ខិណា-ទានមួយកាលពីពេលកន្លងមកនេះនៅឯវត្ត "ប៉ាលេលេយ្យ" នាទីក្រុងហ្វីឡាដែលហ្វៀខាងត្បូងដែលគណកម្មការសម្រាប់បុណ្យនេះត្រូវបានបង្កើតឡើងដោយមានជាច្រើនក្រុមច្រើនបក្សនយោបាយ និងជាច្រើនវត្តអារាម ។ ទោះបីជាបច្ច័យដែលប្រមូលបាននៅសល់ត្រឹមតែ១៩៥០ដុល្លារក្តីតែនេះ បែរជាមានអត្ថន័យដ៏មហាសាលសម្រាប់បងប្អូនខ្មែរក្នុងសហគមន៍ហ្វីឡាដែលហ្វៀដែលពោរពេញដោយក្តីសន្តោស និងអាណិតស្រឡាញ់ដល់មាតុភូមិកំណើតរបស់ពួកគាត់ និងជាមនុស្សខ្មែរដូចគ្នា។

ដោយមានការណែនាំពីលោក "ពិន សំខុន" អគ្គនាយកការផ្សាយនៃកាសែត "ខ្មែរប៉ុស្តិ៍" និងមានការឯកភាពពីគណកម្មការចម្រុះគ្រប់រូបផង ទើបយើងត្រូវបានទទួលភារៈជាអ្នកទទួលលុយទូរស័ព្ទទៅកាន់អតីតអនិកជនខ្មែរ-បារាំងម្នាក់ឈ្មោះលោក "ស៊ូ អេងឡេង" ដើម្បីប្រគល់ថវិកាទាំង១៩៥០ដុល្លារជូនលោក ព្រោះគាត់ជាមនុស្សដែលមានការទុកចិត្តខ្ពស់ពីលោក "ពិន សំខុន" ប្រធានខ្មែរប៉ុស្តិ៍ ហើយលោកក៏ជាមិត្តភក្តិធ្លាប់ធ្វើការសង្គមជាមួយគ្នាកាលពីនៅប្រទេសបារាំងជាពិសេសនោះគឺលោក "អេង ឡេង" នេះហើយជាប្រធានមូលនិធិ "ឆីជី" ដែលមានន័យជាភាសាខ្មែរថា "មូលនិធិករុណាសង្គ្រោះ"។ ដូចការរៀបរាប់របស់យើងនេះហើយទើបមានការណែនាំ និងឯកភាពក្នុងការប្រគល់ថវិការទាំងនោះទៅកាន់លោក អេងឡេង ក្នុងការចាត់ចែងទូទៅលើអំណោយមនុស្សធម៌។

ជាអកុសលក្នុងថ្ងៃបុណ្យចូលឆ្នាំខ្មែរនាពេលនោះលោក អេងឡេង ពុំមានវត្តមាននៅភ្នំពេញឡើយដោយអ្នកទទួលទូរស័ព្ទប្រាប់ថា "គាត់ចេញទៅក្រៅប្រទេស" ។ ប្រមាណជាមួយសប្តាហ៍ក្រោយមកទើបលោក អេងឡេង ហៅទូរស័ព្ទមករកយើងវិញ ។ មួយថ្ងៃបន្ទាប់មក ទើបយើងធ្វើដំណើរទៅកាន់ផ្ទះរបស់លោកនៅឯភ្នំពេញម៉ុស្កុបផ្សារអូឬស្សី ដើម្បីផ្ទេរលុយទាំងនោះជូនលោក ដោយមានលិខិតផ្ទេរប្រាក់ និងលិខិតទទួលដែលសរសេរដោយដៃ ។ លុះថ្ងៃបន្តបន្ទាប់មកទៀត យើងទាំងពីរបានទូរស័ព្ទទាក់ទងគ្នាជាញឹកញាប់ ដើម្បីស្វែងរករូបមន្តល្អណាមួយ ក្នុងការចែកអំណោយព្រោះ "ថវិកាមានចំនួនត្រឹមតែ១៩៥០ដុល្លារ រីឯជនភៀសសឹកមានចំនួនច្រើន" ។ ទាំងអស់នេះជាចំណោទ និងជាបញ្ហាដែលយើងតែងតែពិភាក្សាគ្នាជាញឹកញាប់ ។ ក៏ប៉ុន្តែសម្រាប់យើងបានផ្តល់នូវឱកាសគ្រប់យ៉ាងជូនលោក អេងឡេង ក្នុងការចាត់ចែងទិញសម្ភារៈសម្រាប់ជាអំណោយដល់ជនភៀសសឹកទាំងនោះ ពីព្រោះថ្វីបើលោកជាអនិកជនខ្មែរនៅប្រទេសបារាំងពិតមែន ប៉ុន្តែបច្ចុប្បន្នលោកជាអាជីវករដ៏សមរម្យម្នាក់នៅឯភ្នំពេញ ដូច្នេះលោកអាចសិក្សាដឹងយ៉ាងច្បាស់អំពីតម្លៃទំនិញដែលត្រូវទិញស្របតាមតម្លៃទីផ្សារ។

ទីបំផុតយើងក៏បានរកច្រកចេញ ដោយការទិញអង្ករ និងកៅស៊ូប៉ាតង់សម្រាប់ជាអំណោយមនុស្សធម៌ ដោយផ្នែកខាងអង្ករជាស្បៀងរបស់បងប្អូនខ្មែរនៅហ្វីឡាដែលហ្វៀ រីឯផ្នែកខាងកៅស៊ូប៉ាតង់ជាអំណោយរបស់មូលនិធិ "ករុណាសង្គ្រោះ" ដោយមានលោក ស៊ូ អេងឡេង ជាប្រធានមូលនិធិ ហើយក៏បានសម្រេចយកថ្ងៃទី១ ខែឧសភា ជាថ្ងៃចេញដំណើរ។

នៅថ្ងៃទី១នេះ យើងពុំបានរួមដំណើរជាមួយលោក អេងឡេង និងក្រុមរបស់គាត់ ឡើយព្រោះដោយសាររថយន្តរបស់គាត់ ចង្អៀតពេក ទើបយើងសម្រេចចិត្តជិះរថយន្តឈ្នួលដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ហើយណាត់ជួបគ្នានៅឯសៀមរាប ។ យើងបានសម្រាកមួយយប់នៅទីនោះ លុះព្រឹកឡើងចាប់ផ្តើមចេញដំណើរតាំងពីព្រលឹមម៉ោង៦:០០ ដោយមានរថយន្តពីរគ្រឿង ។ ទីមួយ គឺជារថយន្តផ្ទាល់ខ្លួន-របស់លោក អេងឡេង ជាប្រភេទ Pick-Up មួយបាំងកន្លះ និងមានមនុស្សបួននាក់នៅក្នុងនោះ។

រីឯផ្នែកខាងក្រោយនៃរថយន្តត្រូវបានផ្ទុកទៅដោយកៅស៊ូប៉ាតង់យ៉ាងច្រើនដែលត្រូវបានចងយ៉ាងណែន និងមានសុវត្ថិភាពបំផុត ។ ចំណែកឯទីពីរជារថយន្តដែលយើងជិះដោយមានមនុស្សបីនាក់ ហើយរថយន្តនេះត្រូវបានមូលនិធិ "ករុណាសង្គ្រោះ" របស់លោក អេង ឡេង ជាអ្នកជួលឱ្យសម្រាប់យើងផ្ទាល់ ។

មកដល់ត្រង់ចំណុចនេះ យើងសូមនិយាយជម្រាបមិត្តអ្នកអាន ក៏ដូចជាសប្បុរសជនដែលជាម្ចាស់អំណោយថា គោលដៅចម្បងក្នុងបេសកកម្មមនុស្សធម៌នេះ គឺឆ្ពោះទៅកាន់វត្ត "ចូកគ្រួស" ដែលជាជំរំជនភៀសសឹកដ៏ធំជាងគេក្នុងចំណោមជំរំទាំង១១ នៅក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ ព្រោះទីនោះមានជនភៀសសឹកដល់ទៅ១៨៩៥គ្រួសារ ។ នេះបើតាមរបាយការណ៍ក្រៅផ្លូវការពីមន្ត្រីនៃមន្ទីរអប់រំម្នាក់ឈ្មោះ "សុង" ដែលបានផ្តល់ឱ្យយើង ហើយគាត់ក៏ជាសហការីដ៏សកម្មមួយរូបដែលចូលរួមក្នុងសកម្មភាពមនុស្សធម៌ជាមួយនឹងក្រុមការងាររបស់យើង ។ ហើយតាមរយៈនៃមន្ត្រីអប់រំខេត្តដដែលនេះ លោកក៏ជាសារតាំងក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីសុំការអនុញ្ញាតដើម្បីក្រុមការងារយើងបានចែកអំណោយដល់ជនភៀសសឹក ។ ដោយយល់ថាមានការនឿយហត់ច្រើនទើបលោក សុង ត្រូវបានទទួលសាគុណចំនួន៥០ដុល្លារពីក្រុមការងារមនុស្សធម៌យើង ប៉ុន្តែលុយនោះវាជាថវិកាផ្ទាល់ខ្លួនរបស់លោក ស៊ូ អេងឡេង ប្រធានមូលនិធិ "ករុណាសង្គ្រោះ" ។ សូមជម្រាបបន្ថែមថា "មូលនិធិករុណាសង្គ្រោះ" **(តទៅទំព័រទី១៦)**

តមកពីទំព័រទី ១៦

# បេសកម្មមនុស្សធម៌ដ៏ចម្រូង...

យើងចង់ឃើញជនភៀសសឹកទទួលអំណោយដោយផ្ទាល់ភ្នែក និងចង់ចែកដោយផ្ទាល់ដៃ ប៉ុន្តែពេលទៅដល់វត្ត "ចូកគ្រួស"តាមការកំណត់នោះ ត្រូវបានអាជ្ញាធរមូលដ្ឋានលេបសំដីជាលើកទី២ម្តង ដែលជាហេតុធ្វើឱ្យក្រុមការងារមនុស្សធម៌យើងមានការខកចិត្តសោកស្តាយលាយឡំនិងការខឹងសម្បារយ៉ាងខ្លាំង ។

ប្រិយមិត្តជាទីរាប់អានចំពោះអ្វីដែលយើងនឹកស្មានមិនដល់យល់មិនជ្រៅនោះ គឺទង្វើរបស់អាជ្ញាធរមូលដ្ឋានដែលបានរារាំងមិនឱ្យក្រុមការងារយើងចែកអំណោយឡើយ ក្នុងខណៈដែលជនភៀសសឹកជាច្រើនពាន់គ្រួសារកំពុងតែចាំទទួលអំណោយដោយតក់ក្រហល់នោះ.ទង្វើរដ៏ចម្លែកខុសពីប្រក្រតីបែបនេះ ត្រូវបានទទួលរងនូវការស្តីបន្ទោសយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋដែលជាជនភៀសសឹក ។ ដោយការមិនអស់ចិត្តយើងបានសុំសម្ភាសន៍ជាមួយចៅសង្កាត់ម្នាក់ដែលអះអាងថា ជាអ្នកមើលការខុសត្រូវ និងទទួលបន្ទុកលើជនភៀសសឹកទាំងឡាយក្នុង"វត្តចូលគ្រួស" អំពីមូលហេតុនៃការបដិសេធដមិនព្រមទទួលយកអំណោយពីសប្បុរសជន។ ចំពោះចម្លើយដ៏មិនសមហេតុសមផលរបស់ចៅសង្កាត់ដែលឆ្លើយយករួចខ្លួនបានធ្វើឱ្យយើងចង់ខឹងបន្តិចចង់សើចហួចចិត្តបន្តិច ព្រោះគាត់បានអះអាងថា "នេះជាបញ្ហាចេញពីថ្នាក់លើ"។ មែនទែនទៅតាមការប៉ាន់ស្មានរបស់យើងនេះប្រហែលជាបទបញ្ជាដាច់ខាតចេញពីថ្នាក់លើពិតប្រាកដហើយមើលទៅ ។ រីឯលោកចៅសង្កាត់រូបនោះក៏ពិបាកនឹងឆ្លើយចំពោះសំណួររបស់យើងណាស់ដែរ ។ លោកបានថ្លែងនៅចំពោះមុខជនភៀសសឹកក្នុងខណៈដែលយើងកំពុងតម្រង់ម៉ាស៊ីនថតវីដេអូ (Camara Recorder)ទៅរកគាត់យ៉ាងដូច្នេះថា " ខ្ញុំក៏សោកស្តាយខ្លាំងណាស់ដែរ តែធ្វើម៉េចនេះ ជាបញ្ហាហើយខ្ញុំយល់ណាស់ថា បងប្អូនចង់បានអំណោយពីអស់លោកយ៉ាងប្រាកដ ហើយខាងអស់លោកក៏ចង់ចែកអំណោយដល់បងប្អូនយើងនៅទីនេះដែរ..."

ដោយស្ថានការណ៍ហាក់មិនធូរស្រាល និងមិនអំណោយផលសម្រាប់ក្រុមការងារសប្បុរធម៌យើងទើបតម្រូវឱ្យមានការពិភាក្សាគ្នាយ៉ាងលឿនមួយអំពីយន្តការនៃការចែកអំណោយជាបន្តទៀត តើយើងត្រូវធ្វើយ៉ាងម៉េចបើពេលនេះត្រូវគេមិនឱ្យយើងចែក ? ហើយយើងក៏មិនអាចនៅបង្អែបង្អង់ក្នុងជំរំនៃវត្តចូកគ្រួសយូរទៀតដែរ ព្រោះកម្លាំងប៉ូលិស ប៉េអឹម និងទាហាន ត្រូវបានគេបញ្ជូនមកកាន់វត្តមួយនេះភ្លាមៗដែរ ដែលមើលទៅហាក់ដូចជាចម្លែកខ្លាំងណាស់។

ដោយមានការអាក់ស្រពន់ចិត្តលាយឡំនឹងការខឹងសម្បារចំពោះអាជ្ញាធរមូលដ្ឋានផងនោះលោក ស៊ូ អេងឡេង បានរកដំណោះស្រាយយ៉ាងងាយស្រួលថា"បើគេមិនឱ្យយើងចែកហើយមានតែទៅដូរអង្ករយក លុយត្រឡប់ទៅភ្នំពេញវិញចាំគិតគ្នារឿងចែកអំណោយតាមរបៀបផ្សេងថ្ងៃក្រោយទៀត..."។ យើងក៏មិនជំទាស់នឹងដំណោះស្រាយនេះឡើយ ប៉ុន្តែអង្ករដែលនៅសល់ប្រមាណជា៧០ភាគរយនោះ គឺយើងដូរយកលុយតែពាក់កណ្តាលបានហើយ ទុលពាក់កណ្តាលទៀតសម្រាប់ចែកតាមផ្លូវ! ។នេះជាសំណូមពរដែលយើងចង់បាន ហើយក្រុមការងារទាំងអស់ក៏បានឯកភាព ។ មិនបង្អង់យូរយើងក៏ប្រញាប់ធ្វើដំណើរទៅកាន់រោងម៉ាស៊ីនកិនស្រូវ "អេង សួរ" ដែលនៅមិនឆ្ងាយពីវត្តចូកគ្រួសប៉ុន្មានឡើយ ដើម្បីសុំដូរយកលុយពាក់កណ្តាលវិញ ។ ទីបំផុតម្ចាស់រោងម៉ាស៊ីនក៏យល់ព្រមចំពោះអ្វី ដែលពួកយើងស្នើសុំបន្ទាប់ពីបានអធិប្បាយប្រាប់រឿង ហេតុនៅក្នុងវត្តចូកគ្រួសដល់គាត់ហើយនោះ ប៉ុន្តែតម្លៃអង្ករត្រូវខាតចំនួន៦០ដុល្លារ ថ្លៃកម្លាំងពលកម្មហើយ លុយដែលបានមកវិញនោះ គឺលោក អេងឡេង ជាអ្នកទុកដាក់ ។

អាកាសធាតុកាន់តែក្តៅ ពេលវេលាកាន់ទៃរំកិលទៅមុខជាលំដាប់ដូច្នេះយើងចាំបាច់ត្រូវតែ


"សុំអង្ករមួយការុងមក ខ្ញុំដាច់ពោះហើយ...!"

ប្រញាប់ធ្វើដំណើរត្រឡប់ថយក្រោយ គឺឆ្ពោះទៅកាន់ខេត្តសៀមរាប និងភ្នំពេញជាបន្ទាន់ ។ រថយន្តក៏បានមកដល់ក្លោងទ្វារនៃវត្តចូកគ្រួសជាថ្មី ។ យើងក៏ប្រាប់អ្នកបើកបរឱ្យឈប់មួយភ្លែតហើយចុះពីរថយន្តចូលទៅក្នុងវត្តចូកគ្រួសព្រោះមិនអស់ចិត្តនឹងទង្វើររបស់"ថ្នាក់លើ"ដែលមិនគួររារាំងមិនឱ្យក្រុមការងារយើងចែកអំណោយមនុស្សធម៌ដល់ជនរួមឈាមជាខ្មែរដូចគ្នាឡើយ ហើយចំពោះអ្វីដែលយើងធ្វើនេះ គឺក្នុងនាមមនុស្សធម៌យ៉ាងពិតប្រាកដពោលគឺមិនពាក់ព័ន្ធ ឬយកឈ្មោះគណបក្សនយោបាយណាមួយមកឡកឡំឡើយ។

ក្នុងខណៈដែលយើងដើរចូលទៅកាន់វត្តចូកគ្រួសនេះត្រូវបានបុរសម្នាក់ដែលគេដឹងថាជាមន្ត្រីរាជការថ្នាក់ខេត្តផងនោះ បានប្រាប់យើងដោយប្រុងប្រយ័ត្នថា "បើចងឱ្យប្រជាពលរដ្ឋនៅទីនេះបានទទួលអំណោយលុះត្រាតែក្រុមរបស់លោកប្រគល់របស់ទាំងនោះទៅឱ្យកាកបាទក្រហមកម្ពុជា ឬក៏ទៅឱ្យមូលនិធិបាយ័ន្តជាមុនទើបអាចទៅរួច បើមិនដូច្នេះទេក្រុមរបស់លោកក៏អាចប្រគល់អំណោយទាំងនោះឱ្យទៅគណៈកម្មការនៃវត្តចូកគ្រួសក៏បានដែរ ចាំពួកយើងចាត់ចែងចែកឱ្យប្រជាពលរដ្ឋដោយខ្លួនឯង ពុំចាំបាច់ពិបាកដល់ពួកលោកឡើយ...។ប្រិយមិត្រអ្នកអាចព្រមទាំងសប្បុរជនជាទីរាប់អាន ! សូមជួយពិចារណាផងចុះតើសមហេតុផលដែរឬទេ ។ បងប្អូនខ្មែរ



នៅឯទីក្រុងហ្វីឡាដែលហៀវខំធ្វើបុណ្យដើម្បីប្រមូលបច្ច័យយកមកជួយខ្មែរគ្នាឯង ។ តែត្រូវគេហាមមិនឱ្យចែកបើឱ្យចែកលុះត្រាតែផ្ទេរ របស់ទាំងនោះទៅឱ្យកាកបាទក្រហមកម្ពុជា ដែលមានអ្នកស្រី ប៊ុន រ៉ានី ប្រពន្ធលោក ហ៊ុន សែន ជាប្រធានឬក៏មូលនិធិបាយ័ន្តរបស់ទូរទស្សន៍បាយ័ន្តដែលមាន ហ៊ុន វណ្ណា កូនស្រីបង្កើតរបស់លោក ហ៊ុន សែន នាយិការ ។ តើយើងល្ងង់ខ្លៅព្រមផ្ទេរអំណោយទាំងនោះ ទៅឱ្យក្រុមទាំងពីរដូចបានរៀបរាប់ខាងលើដែរឬទេ? ចម្លើយពិតជាពុំអាចទៅរួចឡើយ ព្រោះអង្ករបានក្លាយ ទៅបាយរួចទៅហើយ បើចង់បានអំណោយទៅឱ្យកាកបាទក្រហម ឬមូលនិធិបាយ័ន្ត គឺរង់ចាំទទួលពីក្រុមផ្សេងទៀតចុះអស់លោកអើយ ព្រោះយើងមានចង់បានប័ណ្ណសរសើរពីអស់លោកថ្នាក់លើទាំងនោះឡើយ។ មិនបង្អង់យូរទៀតឡើយ យើងក៏ប្រញាប់ឡើងរថយន្តឆ្ពោះទៅកាន់ខេត្តសៀមរាបព្រោះថ្ងៃកាន់តែរសៀលជ្រៀសជ្រេរទៅហើយក្រែងយប់ជ្រុលត្រឡប់ទៅភ្នំពេញវិញពុំកើត ។ នៅតាមផ្លូវដែលយើងកំពុងធ្វើដំណើរពីស្រុកសំរោងឆ្ពោះទៅកាន់ខេត្តសៀមរាបយើងសង្កេតឃើញជនភៀសសឹកធ្វើដំណើរតាមគោយន្តជាហូរហែរឆ្ពោះទៅកាន់លំនៅដ្ឋានរៀងៗខ្លួនវិញបន្ទាប់ពីស្ថានការណ៍នៅតាមព្រំប្រទល់មានលក្ខណ្ឌធូរស្រាល។ ដូច្នេះនេះជាឱកាសដ៏សមរម្យមួយសម្រាប់យើងក្នុងការកាត់គោយន្តឱ្យឈប់ ហើយផ្តល់អំណោយដល់ពួកគាត់ ។ មិត្តអ្នកអានជាទីមេត្រី ! តើទង្វើរបស់យើងជាការខុស នឹងបទបញ្ជារបស់ថ្នាក់លើដែរ ឬទេ ? គេហាមមិនឱ្យចែកអំណោយនៅក្នុងជំរំតែយើងនៅតែគឃ្លើនកាក់គោយន្តរបស់បងប្អូនជនភៀសសឹកដែលកំពុងធ្វើដំណើរ ដឹកកូនដឹកចៅចានឆ្នាំងសំពីងសំពោងហើយជូនអង្ករ ដលពួកគាត់ក្នុងមួយគោយន្ត១អង្ករមួយការ៉ុងបែបនេះ ? តាមមើលទៅប្រហែលជាមិនខុសទេដឹង ? ព្រោះគេបានហាមតែនៅក្នុងជំរំទេតើ!ប៉ុន្តែគេពុំបានហាមយើងមិនផឱ្យចែកតាមផ្លូវឯណា ? ហើយយើងបន្តធ្វើសកម្មភាពបែបនេះរហូតទាល់តែអស់អង្ករដែលនៅសេសសល់ទាំងប៉ុន្មាននោះ ។

រឿងរ៉ាវនៅឯវត្ត"ចូកគ្រួស"យើងពុំទាន់ស្ងប់ចិត្តត្រឹមហ្នឹងឡើយ ហើយដោយសារតែយើងធ្លាប់ធ្វើជាអ្នកកាសែតកំប៉ិចកំប៉ុកមួយកាលពីនៅស្រុកខ្មែរជិត១០ឆ្នាំមុនដែរ ទើបធ្វើឱ្យយើងនៅមានទំនាក់ទំនងនិងនៅមានមិត្តភក្តិជាអ្នកព័ត៌មានជាច្រើនអង្គភាពដែរ ។ ដូច្នេះ យើងបានស្វះស្វែងហៅទូរស័ព្ទទៅកាន់អ្នកកាសែតនានា ដើម្បីឱ្យបានដឹងអំពីព័ត៌មានដ៏ចម្លែកនៅឯវត្ត "ចូកគ្រួសនេះ"ប៉ុន្តែមានអ្នកកាសែតមួយចំនួនថា "ម៉េចបានជាលោកឯងមិនប្រគល់អំណោយទាំងហ្នឹងទៅឱ្យកាកបាទក្រហមកម្ពុជា ឬក៏មូលនិធិបាយ័ន្តនោះវាចប់រឿងហើយ...!"។គ្រាន់តែឮនូវអនុសាសន៍ល្ងិល្ងើបែប ហ្នឹងយើងពុំបានសន្ទនាយូរទៀតឡើយ ព្រោះខ្លាចអស់មីនុតទូរស័ព្ទ ដោយសារទូរស័ព្ទមានទឹកប្រាក់ពុំសូវគ្រប់គ្រាន់និងមានកំណត់ ។ ប៉ុន្តែចំពោះអ្វីដែលធ្វើឱ្យយើងស្ងប់ចិត្ត គឺព្រឹកឡើងត្រូវបានវិទ្យុផ្សាយជាភាសាខ្មែរចំនួនពីរនឹងមានស្នាក់ការក្នុងសហរដ្ឋអាមេរិក ព្រមទាំងកាសែតក្នុងស្រុកមួយចំនួនបានចុះផ្សាយនូវព័តិមាននោះយ៉ាងលឿនបំផុតផងដែរ។

យើងសូមបញ្ជាក់រឿងចែកអំណោយនៅឯខេត្តឧត្តរមានជ័យត្រឹមហ្នឹងសិនចុះហើយយើងបែរមកនិយាយរឿងលុយនៅសល់( ១៣៩២ដុល្លារ) វិញម្តង ។ សូមជម្រាបថា ពាក់កណ្តាលនៃចំនួនលុយដែលនៅសល់នោះ( ៦០ភាគរយដុល្លារ )គឺយើងសម្រេចផ្ទេរជូនដល់មូលនិធិ"ករុណាសង្គ្រោះ" របស់លោក ស៊ូ អេងឡេង ចំណែកឯពាក់កណ្តាលទៀត គឺ៦០ភាគរយដុល្លារ ត្រូវយើងធ្វើជាទានដល់ជនទីទ័លក្រ កុមារកំព្រា អ្នកកើតអេដស៍ចាស់ជរាគ្មានទីពុំនាក់ ជនពិកា ក្មេងរើសអេតចាយ និងដូនជី តាជី ដែលស្នាក់នៅក្នុងវត្តដែលមានលក្ខណៈអត្តខាតខ្លាំង... ។ក្រៅពីនោះថវិកាមួយចំនួនត្រូវបានយើងសហការណ៍ជាមួយមូលនិធិ"ករុណាសង្គ្រោះ"ដោយការចុះដល់មូលដ្ឋានផ្ទាល់ក្រុមការងាររបស់លោក អេងឡេង ។

ជាអវសាន្តសូមផល្លានិសង្សកើតមានដល់សប្បុរសជនទាំងឡាយដែលបានចូលរួម ចាប់មគ្គផលជួយដល់បងប្អូនខ្មែរនៅឯប្រទេសកំណើររបស់យើងនិងជូនពរ ឱ្យមានសេរីសួរស្តី សុភង្គលល្អក្នុងគ្រួសារ និងរកទទួលទានមានបានគ្រប់ៗគ្នា។

អត្ថបទនេះនិពន្ធដោយខ្ញុំបាទ អឹម លឿម ជាស្មេរ របស់កាសែតខ្មែរប៉ុស្តិ៍និងជាតំណាងឱ្យប្រជាពលរដ្ឋម្ចាស់អំណោយក្នុងសហគមន៍ខ្មែរនាទីក្រុងហ្វីឡាដែលហៀវដែលបានចុះផ្ទាល់ដល់ជំរំជនភៀសសឹកខ្មែរ ជាច្រើនកន្លែងនៅឯខេត្តបន្ទាយមានជ័យ ។ រូបភាពជាច្រើនទាក់ទងនឹងសកម្មភាពចែកអំណោយ លោកអ្នកអាចចូលទៅកាន់ (Face Book Tony chhoum ) ៕

# បុណ្យអុំទូកនៅហ្វីឡាដែលហ្វៀ



រៀបចំដោយវត្តព្រះពុទ្ធរង្សី
ថ្ងៃសៅរ៍ ទី១០ ខែកញ្ញា ឆ្នាំ០១១
នៅផែនឡេនឌីង មហាវិថី គូឡុមបុស

## The Southeast Asian Dragon Boat Festival

**PENN'S LANDING**
**PHILADELPHIA, PA**
**SATURDAY, SEPTEMBER 10, 2011**
**11:00 AM - 5:00PM**

*EXCITING DRAGON BOAT RACES ♦ FOOD ♦ ASIAN MARKETPLACE ♦ CULTURAL ENTERTAINMENT*

contact :
Song Phou 267-978-3379
www. southeastasiandragonboatfestival.org

សូមអញ្ជើញនាំក្រុមគ្រួសារ និងញាតិមិត្តខ្មែរ និងបរទេសមករួមកំសាន្តការ
ប្រណាំងទូក-ភ្លក់ម្ហូបអាហារ -មើលការតាំងលក់វត្ថុអនុស្សាវរីយ៍ ផ្សារអាស៊ី
មានបង្ហាញសិល្បៈ វប្បធម៌ និងភ្លេងចំម្រៀងខ្មែរ

Sponsored By

PECO
An Exelon Company

Delaware River WATERFRONT Corporation

Presented By

| KHMER BUDDHIST HUMANITARIAN ASSOCIATION, INC. | SOUTHEAST ASIAN DRAGON BOAT FESTIVAL COMMITTEE |
|---|---|

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



**(តមកពីលេខមុន)**

**រៀបរៀងដោយ**

**លោក ម៉ៅ ច័ន្ទសំណុំ**

●●●មេត្តាករុណាការអត់អោនទោសកំហុស និងការដឹងគុណ gratitude សុទ្ធតែជារូបភាពនៃថាមពលវិជ្ជមានដែលមានគុណសម្បត្តិដ៏ឧត្តុង្គឧត្តមដែលអ្នកប្រតិបត្តិសមាធិត្រូវខិតខំបណ្តុះទម្លាប់ឱ្យវារីកធំធាត់ឡើងដើម្បីជាប្រយោជន៍ដល់: **ទី១** ការសំអាតចិត្តមិន Cleansing និង**ទី២** ការបញ្ចូលឱសថដ៏សក្តិសិទ្ធិនាំមកនូវការជាសះស្បើយជម្ងឺផ្លូវចិត្ត និងជម្ងឺរូបកាយសព្វយ៉ាង Mind and Body healing **ទី៣** ការប្រតិបត្តិសមាធិកាន់តែរីកចំរើន ពីព្រោះធាតុទាំងបីនេះ ជាធាតុផ្ទុយនឹងធាតុបុគ្គល ង្សេ ។

-សមាធិមានចរិតបុគ្គលមានន័យថា ដំណើរឈានឡើង និងលទ្ធផលមានទំរង់បែបផែនផ្សេងៗពីបុគ្គលម្នាក់ទៅម្នាក់ៗអាស្រ័យដោយកម្ម ឬទម្រង់ម៉េម៉ីរីនៃបុគ្គលម្នាក់ៗនោះមានលក្ខណៈផ្សេងគ្នា ។ ដោយឡែកខ្ញុំផ្ទាល់បានប្រើចំណុចខ្លះនៃមេត្តាភាវនានៅខាងដើមនៃវគ្គសមាធិម្តងៗ ។ ជាក់ស្តែងជួនកាលខ្ញុំលើកយកចំណុចឱ្យការអភ័យទោសឱ្យ ឬឱ្យការផ្សាយមេត្តាឱ្យ ឬឱ្យការសំដែងដឹងគុណឱ្យមកប្រើ ។ អនុវត្តដូច្នេះខ្ញុំពិសោធន៍ឃើញថា ដំណើរសមាធិមានការចាប់ផ្តើមភាពងាយស្រួល ពីព្រោះមេត្តាភាវនាបានធ្វើឱ្យតួបុគ្គល Ego of mind ថមថយចុះ ហើយបើកផ្លូវឱ្យសមាធិឈានឡើងអស្ចារ្យណាស់ !!! ។

**២-ការអនុវត្តសមាធិជាក់ស្តែង**

ក្រៅអំពីចំណុចលំអិតទ្រឹស្តីខាងលើនេះ ខ្ញុំសូមបន្ថែមចំណុចជាក់ស្តែងមួយចំនួនសំរាប់ជាជំនួយដល់អ្នកដែលមានបំណងចាប់ផ្តើមគិតគូរអំពីសមាធិវិបស្សនានេះ :

**២០កន្លែងហាត់រៀន**

ដើម្បីចាប់ផ្តើមអនុវត្តសមាធិ គួរអ្នកចំណាយពេល១០ថ្ងៃ ចុះឈ្មោះចូលរៀនសាលាដែលមានគ្រូណែនាំត្រឹមត្រូវនៅមជ្ឈមណ្ឌលនានាលើសកលលោក ។ សូមបើករកអស័យដ្ឋាន ក្នុងគេហទំព័រអិនទឺណែត: Vipassana Meditation taught by S.N. Goenka. មជ្ឈមណ្ឌលបង្រៀនបច្ចេកទេសសមាធិមានគ្រប់កន្លែងលើសាកលលោកនៅប្រទេសខ្មែរយើងក៏មានមួយដែរ ។ បើមានបំណងហាត់រៀនសមាធិនៅប្រទេសយើង សូមទាក់ទងទូរស័ព្ទលេខ : (855-012) 689 732 ឬទូរស័ព្ទលេខ (855-012) 488-588 ការចូលរៀននេះ ពុំតម្រូវឱ្យបង់ថ្លៃអ្វីឡើយទាំងកន្លែងស្នាក់នៅទាំងការហូបចុកក្នុងមួយរយៈ ១០ថ្ងៃនេះ ។ ខ្ញុំយល់ថា ការចាប់ផ្តើមហាត់រៀនមានគ្រូ និងមានទីកន្លែងជាការចាំបាច់បំផុត ពីព្រោះការចាប់ផ្តើមដំបូងទាមទារកន្លែងស្ងាត់ដាច់ផុតពីការរស់នៅធម្មតាចំនួន១០ថ្ងៃ **តទៅលេខក្រោយ**


ភោជនីយដ្ឋាន ណាម វាង ( ភ្នំពេញ )
Nam Vang Restaurant

571 Unit#1 Adams Svenue. Philadelphia, PA 19120
(inside Hong Kong Market) (215) 742-9488







រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុក
គ្រប់សេជាតិផ្លែឈើ ដូចជា:
ធុរេន ឬ អាវ្ញូកាដូ ហើយជាពិសេស
មានទឹកអំពៅស្រស់ៗ

១_មុខជំនាញខាងម្ហូបខ្មែរ យ៉ាងចំណាន ដូចជា :
-គុយទាវភ្នំពេញ
-គុយទាវ ឬមី-ខគោ
-មីកន្ត្រាំង ឆាសាច់គោ
-មីកន្ត្រាំងឆាគ្រឿងសមុទ្រ
-បាយឆាគ្រប់មុខ
-សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាម ល្បុយឆ្ងាញ់ ដូចជា :
-នំបញ្ចុកទឹកត្រីពិសេស
-នំប៉័ងបាតេ ឬសាច់គោអាំង
-ខគោ នំប៉័ង ឬ មី និងគុយទាវ
-បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

Open 7 days a week from 9a.m-9p.m
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច



ការិយាល័យច្បាប់

ERIK B.JENSEN P.C
A Profesional Corporation





We Handle All INJURY CASES
- Auto/Bus/Train/Motorcycle
- Slip and Fall / Workplace Accidents
- Medical Malpractice
- Nursing Home Neglect
- Dog Bites / Wrongful Death

Criminal Defense – DUI
Adult & Juvenile
Felonies / Misdemeanors / Drug Offenses
Weapons Charges / Murder / Manslaughter
Robbery / Burglary / Theft / Rape / Child Abuse
Drunk Driving / Traffic Violations

BANKRUPTCY
Sheriff Sales / Foreclosures / Repossessions
Credit Repairs / Tax Liens

FAMILY
Divorce / Support
Alimony / Child Custody
Protection From Abuse
Visitation / Adoptions

BUSINESS
Contracts / Negotiations
Litigation
Start-ups / Financing
Collections

REAL ESTATE
Commercial – Residential
Buying / Selling
Settlements / Closings

TAX PROBLEM
IRS Disputes / Tax Fraud
Audits / Liens / Levies
Tax & Estate Planning

Wills, Estates & Trusts Social Security

FREE Consultation ERIK B. JENSEN, P.C. Attorneys At Law
215-546-4700 24 HOUR AVAILABILITY 800-522-6606
1528 Walnut St., Suite 1401 Philadelphia

មានអ្នកបកប្រែភាសាខ្មែរ
Rely On Over
26 Years Of Experience





WWW.ERIKJENSENLAW.COM
we have Khmer staff





Voun Lay, BS
Marketing Coordinator
267-738-7006

# ជោគជតារាសីទាំង១២ប្រចាំឆ្នាំថោះ

**ឆ្នាំជូត** លោកអ្នកអាចនឹងមានការព្រួយបារម្ភច្រើន ព្រោះតែមានមនុស្សចេះតែតាមឈ្នានីស ឬពុំនោះសោតទេ ក៏អាចមានរឿងរ៉ាវដែលកើតឡើងដោយសារមនុស្សភេទដូយដែរ ដូច្នេះលោកអ្នកត្រូវមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ អាចនឹងមានការខាតបង់យ៉ាងធំ ដូច្នេះមិនគួរដាក់ទុនថ្មីឡើយ ។ រីឯបញ្ហាគូស្នេហ៍ច្រើនតែតោះតើយដាក់គ្នា ៕

**ឆ្នាំឆ្លូវ** រាល់ការបំពេញការងារផ្សេងៗ របស់លោកអ្នកនៅក្នុងពេលនេះមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សខ្ជាត់ខ្ជាយឲ្យសោះ ព្រោះនាំឲ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃបានមកកាក់កប និងអាចសន្សំទុកបាន ។រីឯបញ្ហាស្នេហាគឺគូស្នេហ៍មានស្ថានភាពដូចធម្មតាទេ ៕

**ឆ្នាំខាល** គ្រប់ការងារទាំងអស់ដែលលោកអ្នកត្រូវធ្វើ បើមិនរកអ្នករួមសហការទេ គឺមិនអាចទទួលបានលទ្ធផលល្អឡើយ ហើយបើធ្វើដំណើរតាមយានយន្តលោក អ្នកគួរតែប្រុងប្រយ័ត្នខ្ពស់ផងដែរ ចៀសវាងការកើតមានគ្រោះថ្នាក់ដោយប្រការណាមួយ ។បើជាអ្នកប្រកបមុខរបររកស៊ីវិញគួរជួញដូរនៅទីជិតៗទើបសមប្រកប ។ រីឯបញ្ហាស្នេហា គូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំថោះ** លោកអ្នកមានការឈ្លាសវៃក្នុងការបំពេញការងារផ្សេងៗ ដែលធ្វើឲ្យលោកអ្នកទទួលបានផលសម្រេចតាមគោលដៅដែលអ្នកប្រាថ្នាចង់បានយូរមកហើយ ។ បើ ជាអ្នកប្រកបមុខរបររកស៊ីវិញ អាចមានគេមកបបួលដាក់ទុនរកស៊ីជាមួយដែលលោកអ្នកគួរប្រថុយចុះ ព្រោះមិនខកបំណងទេ ។ រីឯបញ្ហា គូស្នេហ៍រស់នៅជាមួយគ្នាប្រកបទៅដោយភាពផ្អែមល្ហែម ៕

**ឆ្នាំរោង** រាល់ផលប្រយោជន៍ដែលខាតបង់ពីថ្ងៃមុននោះ មកដល់ពេលនេះអាចនឹងស្តារបានឡើងវិញ ខ្លះដាក់ជាពុំខាន ហើយសេចក្តីសុខចំរើនក៏កើតមានដល់លោកអ្នកផងដែរ ។ បើជាអាជីវកររកស៊ីវិញមានការរីកចំរើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

**ឆ្នាំម្សាញ់** រាល់ការងាររបស់លោកអ្នកមានសភាពធ្លាក់ចុះមិនច្បាស់លាស់ ហេតុនេះទាមទារឲ្យលោកអ្នកមានការប្រយ័ត្នប្រយែង និងពុះពារឲ្យបានខ្លាំងជាបន្តទៀត ទើបអាចសម្រេចបានជោគជ័យ ។បើជាអ្នកប្រកបមុខរបររកស៊ីវិញ អាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។រីឯបញ្ហាស្នេហា គូស្នេហ៍រមែងចេះអត់ឱនឲ្យគ្នា ៕

**ឆ្នាំមមី** លោកអ្នកអាចនឹងមានមនុស្សភេទដូយ អាយុស្របាលគ្នាចាំថ្កោលទោសទាញយកផលប្រយោជន៍ ឬពុំនោះសោតទេ ក៏ត្រូវចៅហ្វាយនាយស្តីបន្ទោសពីរឿងការងារ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ មុននឹងទូទាត់បញ្ជីលុយកាក់ គួរតែពិនិត្យផ្ទៀងផ្ទាត់ឲ្យបានម៉ត់ចត់ ចៀសវាងការថ្លោះធ្លោយ ។រីឯបញ្ហាស្នេហា មានការរកាំរកូសគ្នា តែមិនធ្ងន់ធ្ងរ ៕

**ឆ្នាំមមែ** លោកអ្នកអាចនឹងត្រូវចៅហ្វាយនាយ ឬមេការប្រកាន់ថ្នាក់ និងស្តីបន្ទោសមិនបណ្តាក់មាត់ ឡើយបើពុំនោះសោតទេ ក៏អាចមានការទាស់ទែងខ្វែងគំនិតគ្នាជាមួយញាតិពន្ធ ដែលជាអ្នកជិតស្និទ្ធផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចត្រូវខាតដើមដោយចៀសពុំរួចនោះទេ ដូច្នេះលោកអ្នកមិនគួរបោះទុនធំឡើយ ។ រីឯបញ្ហាស្នេហាច្រើនកើតរឿងឈ្លោះប្រកែកគ្នា ដោយសារអ្នកដទៃ ៕

**ឆ្នាំវក** លោកអ្នកអាចនឹងត្រូវមនុស្សសម្បុរសមកបញ្ចុះបញ្ចូលចិត្តឲ្យដើរទៅរកផ្លូវមិនល្អ ហេតុនេះបើសិនជាមានមែននោះ ចូរកុំរវីរវល់ជាមួយឲ្យសោះ ព្រោះអាចបណ្តាលឲ្យមានក្តីវិនាសអន្តរាយដល់ខ្លួនបាន ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តី គួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឲ្យខាតបង់ ។ រីឯបញ្ហាស្នេហា គូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

**ឆ្នាំរកា** គ្រប់កិច្ចការទាំងអស់ដែលលោកអ្នកស្រវាស្រទេញបំពេញបានផលយ៉ាងគាប់ប្រសើរ ព្រោះមានអ្នកចាំជួយជ្រោមជ្រែងគ្រប់ពេលវេលា ។ បើជាអាជីវកររកស៊ីវិញ អាចរកប្រាក់ចំណេញបានយ៉ាងច្រើន ហើយងាយស្រួលទៀតផងជាមួយនេះ ក៏អាចពង្រីកមុខរបរបានថែមទៀត ។រីឯបញ្ហាស្នេហា គ្មានអ្វីគួរឲ្យកត់សំគាល់ឡើយ ៕

**ឆ្នាំច** រាល់ការបំពេញភារកិច្ចប្រចាំថ្ងៃ ទោះបីជាមានការធុញថប់ក្តី ព្រោះមានអ្នកជួយជ្រោមជ្រែងគ្រប់ពេលវេលា ដូច្នេះលោកអ្នកមិនត្រូវអស់សង្ឃឹមឡើយ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ រកផលកម្រៃកាក់កបគ្រាន់បើ ថែមទាំងអាចសន្សំទុកដាក់បានខ្លះទៀតផង ។រីឯបញ្ហាស្នេហា គូស្នេហ៍ច្រើល មើលបំណាំគ្នា ៕

**ឆ្នាំកុរ** លោកអ្នកច្រើនជួបនឹងការបរាជ័យទាំងក្នុងការបំពេញការងារទាំងការចេញទៅទាក់ទងនៅក្រៅ ហើយបើមានការធ្វើដំណើរទៅទីឆ្ងាយនោះក៏ត្រូវមានការប្រុងប្រយ័ត្នផងដែរ ។បើជាអ្នកប្រកបមុខរបររកស៊ីវិញ លោកអ្នកមិនគួរប្រថុយប្រថានដាក់ទុនធំពេកនោះទេ ព្រោះអាចនាំឲ្យមានការខាតបង់ ។រីឯបញ្ហាស្នេហា គូស្នេហ៍ច្រើនពាក់មុខយក្សដាក់គ្នាខុសទំនង ៕

# បោកឈុតក្នុងខាយៗតែជ្រះល្អ



●រឿងបោកជម្រះឈុតក្នុងនេះ គឺទាមទារឲ្យបានស្អាត តែទន្ទឹមគ្នានោះដែរ ក៏ត្រូវធ្វើការព្យាយាមមិនអន់ប៉ុន្មានដែរ ទើបធានាបានទាំងសុវត្ថិភាព និងគុណភាព ។ តទៅនេះ គឺជាវិធីសម្អាតឈុតក្នុងបែបងាយ ហើយធានាថាមានប្រសិទ្ធភាពបំផុត ។

●គួរបំបែកខោអាវឈុតក្នុង និងឈុតក្រៅមុនពេលបោករាល់លើក ។

●គួរប្រើម្សៅសាប៊ូលាយនៅក្នុងទឹកជាមុនសិន ឬអាចប្រើប្រភេទសាប៊ូដែលតម្រូវឲ្យប្រើជាមួយខោអាវឈុតក្នុង ។ មិនគួរប្រើសាប៊ូ ឬប្រើអូសាវ៉ែលគ្រប់ប្រភេទបោកឈុតក្នុងដាច់ខាត ។

●បោកដោយដៃថ្នមៗ មិនណែនាំឲ្យប្រើច្រាស់ដុសដែលអាចធ្វើឲ្យឆាប់យារខូច ។

●គួរបោកជម្រះទឹកសាប៊ូឲ្យបានច្រើនទឹករហូតដល់មានទំនុកចិត្តថាជ្រះជាតិសាប៊ូអស់ ។

●គួរហាលឈុតក្នុងនៅក្នុងទីម្លប់ និង-មានខ្យល់បក់ខ្លាំង ។ មិនគួរហាលនៅកណ្តាលកំដៅថ្ងៃក្តៅ ព្រោះអាចធ្វើឲ្យឆ្លកពណ៌ និងខូចគុណភាព ៕

សោភ័ណភាព

# អាំងពោតឱ្យមានរសជាតិឆ្ងាញ់

●●●ពោតអាំងប្រសិនបើអ្នកអាំងដោយមិនយល់ពីអាថ៌កំបាំងវាទេ នោះសាច់ពោត



របស់អ្នកនឹងមានសភាពក្រៀមរីងដូចពោតទុំថែមទាំងគ្មានរសជាតិទៀតផង ។ ដើម្បីឲ្យពោតអាំងរបស់អ្នកមានឱជារសឆ្ងាញ់ជាប់ចិត្តដំបូងសូមប្រចាប់យកក្បាលខ្ទិះដូងទៅលាយជាមួយស្ករ និងអំបិលឲ្យមានរសជាតិប្រៃផ្អែម ។ បន្ទាប់មកយកផ្លែពោតទៅជ្រលក់ត្រាំនៅក្នុងទឹកនោះទើបដាក់អាំងរហូតដល់ឆ្អិន ។ លើកនេះធានាថា សាច់ពោតអាំងរបស់អ្នកមិនត្រឹមតែមានរសជាតិឈ្ងុយ ហើយឆ្ងាញ់ប៉ុណ្ណោះទេ វាថែមទាំងមានសាច់ជ្រាយទន់ងាយទំពាទៀតផង ៕



# កំចាត់រុយដោយម្ទេសក្រៀម

●នរណាៗក៏ទទួលស្គាល់ថា សត្វរុយ គឺជាសត្វប្រភេទដែលចម្លងនូវមេរោគបានយ៉ាងងាយបំផុតដែរ គឺវារោមតែរបស់ណាដែលស្មោកគ្រោក ធ្វើឲ្យមេរោគជាប់នៅតាមជើងរបស់វា ហើយចម្លងមកកាន់មនុស្សនៅពេលវាមកទុំលើចំណីអាហារដែលយើងត្រូវទទួលទាន ។

សត្វរុញនេះក៏ជាសត្វរំខានដល់ស្ត្រីមេផ្ទះខណៈពេលនាងធ្វើម្ហូបអាហារប្រចាំថ្ងៃទៀតផង ។ ក៏ប៉ុន្តែ ប្រសិនបើចង់ដោះស្រាយរឿងនេះ នោះគឺជាការងាយបំផុតដោយគ្រាន់តែ សូមណែនាំឲ្យស្ត្រីមេផ្ទះនាងយកម្ទេសក្រៀមប្រហែល៥-៦គ្រាប់យកទៅដោតសៀតនៅជុំវិញកញ្ច្រែង សាច់ ឬបន្លែ ឬក៏កញ្ច្រែងដែលដាក់ហាលសាច់ជាដើម នោះសត្វរុយពិតជាពុំហ៊ានមករំខានទៅទៀតឡើយ ៕


Massachusetts Council on
Compulsive Gambling
We understand the problem. We can help.
ក្រុមប្រឹក្សារដ្ឋម៉ាសាឈូសេតសំរាប់
ការញៀនល្បែងស៊ីសង
"ប្រសិនបើលោកអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់
មានបញ្ហាញៀនល្បែងស៊ីសង សូមទូរស័ព្ទមកលេខ
ខាងក្រោម អាចជួយជាអ្នកសម្ងាត់ ហើយ
សួររកសៀវភៅសម្រាប់ឱ្យអាចជួយខ្លួនឯងបាន
ជាភាសាខ្មែរដោយឥតគិតថ្លៃ"
1-857-383-3577
ជំហានដំបូងរបស់អ្នកឆ្ពោះទៅកាន់ការផ្លាស់ប្តូរ
www.asianproblemgambling.org


NEW
CHINA PEARL
DIM SUM (All Day, EveryDay)
288 Mishawum Rd., Woburn, MA 01801
Phone:(781) 932-0031/Fax: (781) 932-0346
www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell
93 South; Exist 37B, from RT-128; Exit 36.
ភោជនីយដ្ឋានញូឆាណាភើលសូមអញ្ជើញលោកអ្នក
និងក្រុមគ្រួសារមករីករាយជាមួយម្ហូបអាហារមកពី
ហុងកុង និងប្រទេសអាស៊ីនានាជុំវិញ ។យើងមានសាលរាំ
កំសាន្តសំរាប់ ពិធីការ ឬរាត្រីជួបជុំគ្នាមានបា និងខារ៉ាអូខេ
ទៀតផង កន្លែងចតឡានមិនយកថ្លៃ ហើយមានសុវត្ថិភាពល្អ ។
新龍鳳大酒樓
ZAGAT RATED
ZAGAT
ZAGAT.COM
Very Good to Excellence Food,
Boston Restaurants,
2011/2012"
Restaurant & Bar
ភោជនីយដ្ឋាន និងបា
ភោជនីយដ្ឋាន ញូ ឆាយណា ភើល
Ballrooms for Wedding & Party
មានឆាករាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត
ការ៉ាអូគី Karaoke
Thursday – Saturday Night
8 p.m. – 11:45 p.m.
មានឌិនស៊ុមរាល់ថ្ងៃ DAILY DIM SUM
Weekdays: 11 a.m.–3 p.m.
Weekends: 10 a.m.-3 p.m.
BUSINESS HOURS: Mon - Wed 11 a.m. - 10 a.m./Thurs. & Fri. 11 a.m. - 12 Midnight / Sat. 10 a.m. - 12 Midnight / Sun. 10 a.m. - 10 p.m. Delivery Hours 11 a.m. - 9 p.m. min. $15 order plus $2 delivery.






# COMMUNITY OF KHMER BUDDHIST MONKS USA FUTURE TEMPLE SITE

**SITE 1 - 104 TOWNSEND AVE./ SITE 2 - 800.1 VARNUM AVE./ SITE 3 - 810 VARNUM AVE.**
**LOWELL, MA 01852**

***PREPARED BY 4SQUARES BUILDING DESIGN***
***& D.P EVERS ARCHITECTURE***

**មណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ ស.រ.អា.**

**Community of Khmer Buddhist Monks Center U.S.A.**

P.O. BOX 653
North Chelmsford, Massachusetts 01863
Tel: (978) 251-2709, Fax: (978) 251-1198
www.ckbm.org

## លិខិតថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាព ព្រះសង្ឃាធិបតី **សៅ ឃន** (ធម្មថេរោ) ប្រធានសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក (CKBM) សូមនមស្សការព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរព និងចម្រើនពរញាតិញោមពុទ្ធបរិស័ទ សប្បុរសជនទាំងឡាយជាទីរាប់អាន ។

កាលពីថ្ងៃអាទិត្យ៨កើត ខែស្រាពណ៍ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី៧ ខែសីហា ឆ្នាំ២០១១ កន្លងមកនេះ, សហគមន៍ព្រះសង្ឃខ្មែរ ដោយមានការគាំទ្រពីពុទ្ធបរិស័ទនិងសប្បុរសជនទាំងឡាយ បានរៀបចំបុណ្យផ្កាប្រាក់សាមគ្គីមួយ នៅភោជនីយដ្ឋានសំពៅមាស ទីក្រុងឡូវែល រដ្ឋម៉ាស្សាជូសេត ដើម្បីប្រមូលបច្ច័យសម្រាប់ជួយឧបត្ថម្ភ ដល់តម្លៃជាវដីកសាងវត្តធ្វើជាមជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក ។ នៅថ្ងៃបុណ្យផ្កាប្រាក់សាមគ្គីនោះ គឺជាព្រឹត្តការណ៍មួយប្រកបដោយមោទនភាព និងកិត្តិយសខ្ពង់ខ្ពស់ក្រៃលែង ដោយមានព្រះសង្ឃ ញាតិញោមពុទ្ធបរិស័ទ សប្បុរសជន និងអ្នកមុខអ្នកការ បាននិមន្តនិងអញ្ជើញមកពីរដ្ឋម៉ាស្សាជូសេត រដ្ឋរ៉ូដអាយឡែនដ៍ រដ្ឋម៉េន ទីក្រុងញូយ៉ក រដ្ឋខណិតធិខិត រដ្ឋជានីវ៉ាស៊ិនតោនឌីស៊ី និងរដ្ឋផ្សេងៗទៀត ពិសេសពុទ្ធបរិស័ទទីក្រុងឡូវែល និងទីក្រុងលីន សរុបជាង១០០០នាក់ បាននិមន្តនិងអញ្ជើញចូលរួម ក្នុងពិធីបុណ្យនោះយ៉ាងច្រើនកុះករដែលមិនធ្លាប់មាន ។ ពិធីបុណ្យផ្កាប្រាក់សាមគ្គីនេះ បានទទួលលទ្ធផលបច្ច័យសរុបចំនួន $127,462 ដុល្លារ និង 50 សេន (ដប់ពីរម៉ឺនប្រាំពីរពាន់ បួនរយ ហុកសិបពីរដុល្លារ និងហាសិបសេន) ។

ជាមួយគ្នានេះ, ខ្ញុំព្រះករុណាអាត្មាភាព ក៏សូមប្រគេននិងជម្រាបពត៌មាន ឲ្យបានជ្រាបផងដែរថា សហគមន៍ព្រះសង្ឃខ្មែរ បានជាវដីមួយកន្លែងមានទំហំ 12 អេក៏ (ជិត5ហិកតា) ស្មើនិងផ្ទៃដី 48,572 ម៉ែត្រក្រឡា ស្ថិតនៅក្នុងក្រុងឡូវែល រដ្ឋម៉ាស្សាឈូសេត ក្នុងតម្លៃមួយលានដុល្លារសហរដ្ឋអាមេរិក ។ សូមបញ្ជាក់ថា ដីវត្តនេះជាកម្មសិទ្ធិរបស់សហគមន៍ព្រះសង្ឃខ្មែរ ដែលត្រូវបានចុះព្រះហស្តលេខាលើកិច្ចទទួលសិទ្ធិ (Deed) គ្រប់គ្រង កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដោយព្រះសង្ឃជាមហាថេរៈចំនួន ១០ អង្គ ។

ក្នុងនាមប្រធានសហគមន៍ព្រះសង្ឃខ្មែរ ខ្ញុំព្រះករុណាអាត្មាភាពសូមសម្តែងនូវកតញ្ញុតាធម៌ និងការកោតសរសើរដោយស្មោះអស់ពីដួងចិត្ត ព្រមទាំងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះថេរានុត្ថេរគ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទសប្បុរសជនទាំងអស់ ដែលបានចូលរួមឧបត្ថម្ភគាំទ្រ ក្នុងពិធីបុណ្យផ្កាប្រាក់សាមគ្គីកន្លងមកនេះ ក៏ដូចជាការជួយគាំទ្រដល់បេសកកម្មរបស់សហគមន៍ព្រះសង្ឃខ្មែរកន្លងមក និងទៅអនាគតផងដែរ ។

សហគមន៍ព្រះសង្ឃខ្មែរ សូមប្រសិទ្ធិពរជ័យសិរីសួស្តីមហាប្រសើរ ប្រគេននិងជូនដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ញាតិញោមពុទ្ធបរិស័ទនិងសប្បុរសជនទាំងអស់ នូវពុទ្ធពរទាំងឡាយ ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្បត្តិ៣ មនុស្ស ទេវតា និងព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

ធ្វើនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១១

ប្រធាន

ព្រះសង្ឃាធិបតី **សៅ ឃន** (ធម្មថេរោ)